ជូនចំពោះ មាតាបិតា និង អាណាព្យាបាល៖

កាលពី ពីរបីថ្ងៃកន្លងទៅនេះ ការវាយតប់ដាច់ដោយឡែកពីគ្នាមកលើអ្នករដ្ឋបាលសាលា បាននាំឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅក្នុងសហគមន៍សាលារបស់យើង។ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា បានប្តេជ្ញារក្សា សុវត្ថិភាព និង សុខុមាលភាព របស់ សិស្ស និង បុគ្គលិក របស់យើង។ យើងមិន អាចទទួលយក និង មិនអាចអត់ឱនឲ្យបាន នូវការវាយតប់មកលើអ្នករដ្ឋបាលពីរនាក់នោះទេ។ ឳពុកម្តាយគឺជាដៃគូដ៏សំខាន់របស់យើងក្នុងការអប់រំកូនៗរបស់ពួកគាត់ ហើយដោយសារមូលហេតុនេះហើយ បានជាយើងធ្វើការដើម្បីធានាដល់ការគោរពនូវការចូលរួមរបស់ពួកគាត់នៅក្នុងសាលា។ ក្នុងខណៈពេលដែលយើងមានទស្សនៈខុសគ្នា យើងមិនអនុញ្ញាតឱ្យមានការរំលោភបំពានដល់រាងកាយនោះទេ។ យើងកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហានេះជាមួយអាជ្ញាធរផ្នែកសុវត្ថិភាពសាធារណៈ និងសហការយ៉ាងពេញលេញជាមួយការស៊ើបអង្កេតពីបញ្ហានេះ។

ក្នុងពេលដែលយើងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់យើងរវាង សាលា ផ្ទះ និង សហគមន៍ យើងក៏ត្រូវការជំនួយពីលោកអ្នកផងដែរ។ បើសិនជាលោកអ្នកត្រូវការ ការគាំទ្រ ឬ ជំនួយ សម្រាប់កូនរបស់លោកអ្នកនៅសាលា យើងសំណូមពរឲ្យលោកអ្នកទូរស័ព្ទទៅ ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង មសហគមន៍ លេខ (២១៥) ៤០០-៤០០០ អ៊ីម៉ែល៖ ask@philasd.org ឬ ស្នើសុំការជួបប្រជុំជាមួយអ្នកធ្វើទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់សាលាលោកអ្នក។

ការរួបរួមគ្នាក្នុងនាមជាសហគមន៍ដើម្បីដោះស្រាយបញ្ហា អាចជួយយើងក្នុងការធានាថាសិស្សនឹងមានសុវត្ថិភាព និងអនុញ្ញាតឱ្យយើងបន្តភារកិច្ចអប់រំដ៏សំខាន់។

ដោយសេចក្តីគោរព
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា